# ថ្នាំបង្ការជំងឺ COVID-19 សម្រាប់យុវជន

# សំណួរដែលត្រូវបានសួរជាញឹកញាប់សម្រាប់ឪពុកម្តាយនិងអាណាព្យាបាល

**មនុស្សវ័យក្មេងដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំមានសិទ្ធិទទួលថ្នាំបង្ការជំងឺ COVID-19 ដែលផលិតដោយក្រុមហ៊ុន Pfizer។**

**ការចាក់ថ្នាំបង្ការគឺឥតគិតថ្លៃជានិច្ច។ ទាំងអ្នក ឬក៏កូនរបស់អ្នកនឹងមិនត្រូវបានសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។**

**សូមចូលទៅកាន់គេហទំព័រ៖ VaccinateLACounty.com ឬ VacunateLosAngeles.com (ភាសាអេស្ប៉ាញ) ដើម្បីស្វែងរកព័ត៌មាននៃការចាក់ថ្នាំបង្ការ។**

### ហេតុអ្វីបានជាកូនរបស់ខ្ញុំគួរតែចាក់ថ្នាំបង្ការជំងឺ COVID-19?

កុមារច្រើនជាង 4 លាននាក់ (ចាប់ពីអាយុ 0 ដល់ 17 ឆ្នាំ) បានធ្វើតេស្តទទួលលទ្ធផលវិជ្ជមានសម្រាប់ជំងឺ COVID-19 នៅសហរដ្ឋអាមេរិកចាប់តាំងពីការចាប់ផ្តើមមានរោគរាតត្បាតសកលនេះ។ ទោះបីជាជំងឺ COVID-19 ច្រើនតែស្រាលចំពោះកុមារជាងមនុស្សធំ ក៏កុមារមួយចំនួនអាចធ្លាក់ខ្លួនឈឺខ្លាំង ឬមានបញ្ហាសុខភាពយូរអង្វែងដែលបង្ករមកពីជំងឺ COVID-19 ដែរ។ ការចាក់ថ្នាំបង្ការឱ្យកូនរបស់អ្នកកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគដែលបង្ករឱ្យមានជំងឺ COVID-19។ ថ្នាំបង្ការនេះក៏នឹងការពារប្រឆាំងនឹងរោគសញ្ញានៃការរលាកពហុសរីរាង្គចំពោះកុមារ (MIS-C) ដែលជាស្ថានភាពដ៏កម្រ ប៉ុន្តែអាចមានភាពធ្ងន់ធ្ងរចំពោះមនុស្សវ័យក្មេងដែលមានជំងឺ COVID-19។

កុមារតូចៗដែលឆ្លងជំងឺ COVID-19 អាចចម្លងមេរោគនេះទៅកាន់អ្នកដទៃ ទោះបីជាពួកគេមិនមានអារម្មណ៍ថាមិនស្រួលខ្លួនក៏ដោយ។ ការចាក់ថ្នាំបង្ការជួយការពារមិត្តភក្តិ និងក្រុមគ្រួសារជាច្រើន ក៏ដូចជាសហគមន៍ទាំងមូលផងដែរ។ នេះរួមបញ្ចូលទាំងការការពារមនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយ និងកុមារអាយុក្រោម 12 ឆ្នាំដែលមិនទាន់អាចចាក់ថ្នាំបង្ការបាន។

នៅពេលដែលកូនរបស់អ្នកត្រូវបានចាក់ថ្នាំបង្ការពេញលេញ វាមានសុវត្ថិភាពសម្រាប់ពួកគេដើម្បី ជួបជុំជាមួយមិត្តភក្តិ លេងកីឡា និងទៅសួរសុខទុក្ខក្រុមគ្រួសារ។ ពួកគេនឹងមិនតម្រូវឱ្យធ្វើតេស្តរកមេរោគដើម្បីលេងកីឡាទេ។ ពួកគេក៏មិនចាំបាច់ត្រូវធ្វើចត្តាឡីស័កផងដែរ ប្រសិនបើពួកគេធ្វើដំណើរទៅក្រៅរដ្ឋ ឬប្រសិនបើមិត្តភក្តិ សមាជិកគ្រួសារ គ្រូបង្រៀន ឬមិត្តរួមក្រុមមានជំងឺ COVID-19 នោះ។

### តើថ្នាំបង្ការជំងឺ COVID-19 មួយណាដែលកូនរបស់ខ្ញុំអាចចាក់បាន?

យុវជនដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំអាចចាក់ថ្នាំបង្ការប្រភេទ Pfizer បាន។ ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាទូទៅដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) សម្រាប់បង្ការជំងឺ COVID-19 ចំពោះមនុស្សដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅ។ ថ្នាំបង្ការនេះត្រូវបានអនុញ្ញាតដោយ FDA សម្រាប់ការប្រើប្រាស់បន្ទាន់នៅចំពោះមនុស្សដែលមានអាយុពី 12ដល់17 ឆ្នាំ។

ថ្នាំបង្ការប្រភេទ Moderna និងប្រភេទ Johnson & Johnson ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាទូទៅសម្រាប់តែមនុស្សដែលមានអាយុលើសពី 18 ឆ្នាំប៉ុណ្ណោះនៅពេលនេះ។ ក្រុមហ៊ុន Moderna បានដាក់ពាក្យស្នើសុំឱ្យថ្នាំបង្ការរបស់ពួកគេទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ក្រុមមនុស្សចាប់ពីអាយុ 12 ទៅ 17 ឆ្នាំ។ បច្ចុប្បន្ននេះក្រុមហ៊ុន Johnson & Johnson កំពុងធ្វើតេស្តសាកល្បងថ្នាំបង្ការបែបវេជ្ជសាស្ត្រ (clinical trials) ទៅលើក្មេងអាយុ 12 ដល់ 17 ឆ្នាំផងដែរ។

ដើម្បីស្វែងយល់បន្ថែមអំពីថ្នាំបង្ការនេះ សូមមើលតារាងព័ត៌មានពិតនៃថ្នាំបង្ការនីមួយៗសម្រាប់អ្នកទទួលចាក់ថ្នាំបង្ការ និងអ្នកផ្តល់ការថែទាំទាំងអស់៖ ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer-BioNTech ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Moderna និង ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ J&J/Janssen។

### ហេតុអ្វីបានជាថ្នាំបង្ការនេះមានសម្រាប់តែយុវជនដែលមានអាយុលើសពី 12 ឆ្នាំយ៉ាងនេះ? តើនៅពេលណាដែលក្មេងតូចៗអាចចាក់ថ្នាំបង្ការបាន?

កុមារអាយុក្រោម 12 ឆ្នាំមិនអាចទាន់ចាក់ថ្នាំបង្ការបានទេ ពីព្រោះមិនទាន់មានព័ត៌មានគ្រប់គ្រាន់អំពីរបៀបដែលថ្នាំបង្ការទាំងនេះដំណើរការទៅលើកុមារនៅក្នុងក្រុមអាយុនេះ។ ការសិក្សាតាមបែបវេជ្ជសាស្ត្រ (clinical

studies) នៅតែកំពុងធ្វើឡើងលើកុមារអាយុក្រោម 12 ឆ្នាំ។ ដោយផ្អែកលើលទ្ធផលនៃការសាកល្បងទាំងនោះ ក្រុមអាយុវ័យក្មេងនានាអាចមានសិទ្ធិទទួលថ្នាំបង្ការនៅចុងរដូវស្លឹកឈើជ្រុះ ឬដើមរដូវរងា។

### តើខ្ញុំអាចចាក់ថ្នាំបង្ការសម្រាប់កូនវ័យជំទង់របស់ខ្ញុំនៅទីណាបាន?

ថ្នាំបង្ការត្រូវបានផ្តល់ជូននៅទីតាំងរាប់រយកន្លែងនៅទូទាំងខោនធី LA រួមមានកន្លែងចាក់ថ្នាំបង្ការជំងឺ COVID-19 ពិសេស គ្លីនិក ឱសថស្ថាន សាលារៀន និងកន្លែងចល័តជាច្រើនទៀត។ ទីតាំងជាច្រើនមិនតម្រូវឱ្យធ្វើការណាត់ជួបទេ។ តាមដានមើលទីតាំងគ្លីនិកដែលមានផ្តល់ជូនថ្នាំបង្ការនៅក្នុងតំបន់របស់អ្នក។ ការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏អាចផ្តល់ជូនផងដែរសម្រាប់មនុស្សដែលមិនអាចធ្វើដំណើរចេញពីផ្ទះបាន។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com ហើយ ចុចលើ "របៀបទទួលការចាក់ថ្នាំបង្ការ" ("How to Get A Vaccine")។ អ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការតាមរយៈលេខទូរស័ព្ទ 833-540-0473។ កន្លែងនេះបើកបម្រើការជូនជារៀងរាល់ថ្ងៃចាប់ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់។ ប្រសិនបើអ្នកកំពុងស្វែងរកថ្នាំបង្ការសម្រាប់ក្មេងអាយុពី 12 ដល់ 17 ឆ្នាំ ត្រូវប្រាកដថាជ្រើសរើសទីតាំងដែលផ្តល់ថ្នាំបង្ការប្រភេទ Pfizer។

### តើខ្ញុំត្រូវការយកឯកសារអ្វីខ្លះទៅមួយដើម្បីចាក់ថ្នាំបង្ការសម្រាប់កូនវ័យជំទង់របស់ខ្ញុំ?

យុវជនដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំត្រូវការភស្តុតាងបញ្ជាក់ពីអាយុ និងការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ដើម្បីទទួលបានការចាក់ថ្នាំបង្ការ។ ក្រុមគ្រួសារគួរតែពិនិត្យមើលកន្លែងដែលពួកគេមានគម្រោងថានឹងទៅចាក់ថ្នាំបង្ការ ដើម្បីស្វែងយល់អំពីតម្រូវការនៃកិច្ចព្រមព្រៀងអនុញ្ញាតរបស់កន្លែងទាំងនោះ។ អ្នកក៏អាចពិនិត្យមើលអ៊ីមែល ឬសារជាអក្សរដែលអ្នកទទួលបាននៅពេលអ្នកធ្វើការណាត់ជួប ដើម្បីដឹងថា ឯកសារអ្វីដែលអ្នកត្រូវយកភ្ជាប់ទៅជាមួយ។ ប្រសិនបើអ្នកទៅទីតាំងដែលអ្នកមិនចាំបាច់ធ្វើការណាត់ជួប សូមយកឯកសារដែលបង្ហាញពីភស្តុតាងនៃអាយុរបស់កូនអ្នកទៅជាមួយ។ សម្រាប់ព័ត៌មានអំពីតម្រូវការនានានៅទីតាំងចាក់ថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com ឬទូរស័ព្ទទៅមជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការ (សូមមើលខាងលើ)។

### តើយុវជនដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំទទួលថ្នាំបង្ការដែលមានកម្រិតតិចជាងមនុស្សពេញវ័យមែនឬទេ?

ទេ។ កម្រិតថ្នាំបង្ការប្រភេទ Pfizer គឺមានដូសដូចគ្នាសម្រាប់យុវជន (អាយុ 12 ដល់ 17 ឆ្នាំ) និងមនុស្សពេញវ័យ។ ថ្នាំបង្ការមានចាក់ជូនចំនួន 2 ដូស ដោយមានគម្លាត 21 ថ្ងៃពីគ្នា។ វាជាការចាំបាច់ក្នុងការចាក់ដូសទីពីរ ដើម្បីទទួលបានការការពារពេញលេញពីថ្នាំបង្ការនេះ។ កូនរបស់អ្នកនឹងបានចាក់ថ្នាំបង្ការពេញលេញ 2 សប្តាហ៍បន្ទាប់ពីពួកគេបានចាក់ដូសទីពីរ។

### តើមានផលប៉ះពាល់អ្វីខ្លះចំពោះយុវជន?

ផលប៉ះពាល់នៃថ្នាំបង្ការគឺស្រដៀងគ្នារវាងកុមារ និងមនុស្សពេញវ័យ។ រោគសញ្ញាទាំងនោះអាចរួមមានឈឺដៃ គ្រុនក្តៅ មានអារម្មណ៍អស់កំលាំង គ្រុនរងា ឈឺក្បាល និងចង្អោរចង់ក្អួត។ ផលប៉ះពាល់ទាំងនេះអាចដាក់កម្រិតលើសកម្មភាពប្រចាំថ្ងៃមួយចំនួន ប៉ុន្តែគួរតែបាត់ទៅវិញក្នុងរយៈពេលពីរទៅបីថ្ងៃ។ មិនមែនមនុស្សគ្រប់គ្នានឹងទទួលបានផលប៉ះពាល់ទាំងនេះទេ។ ផលប៉ះពាល់ទាំងនេះគឺធម្មតា និងជាសញ្ញាដែលបង្ហាញថារាងកាយកំពុងបង្កើតភាពស៊ាំ។

### តើកូនរបស់ខ្ញុំអាចចាក់ថ្នាំបង្ការប្រឆាំងជំងឺ COVID-19 និងប្រឆាំងជំងឺដទៃទៀតក្នុងពេលតែមួយបានដែរឬទេ?

បាទ/ចាស បាន។ កុមារដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅអាចចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលជាមួយថ្នាំបង្ការដទៃទៀត ដូចជាជំងឺគ្រុនផ្តាសាយ និងក្អកមាន់។ ប្រសិនបើកូនរបស់អ្នកចាក់ថ្នាំបង្ការជំងឺ COVID-19 នៅកន្លែងដែលមិនមានផ្តល់ថ្នាំបង្ការផ្សេងទៀតដែលពួកគេត្រូវការ អ្នកអាចទៅកាន់ទីតាំងផ្សេងដើម្បីចាក់ថ្នាំបង្ការទាំងនោះនៅពេលណាក៏បាន។ មិនចាំបាច់ចំណាយពេលរង់ចាំសម្រាប់ចាក់ថ្នាំបង្ការផ្សេងគ្នានោះទេ។

### តើមនុស្សដែលមានប្រតិកម្មអាលែកហ្ស៊ី អាចទទួលថ្នាំបង្ការជំងឺ COVID-19 បានដែរឬទេ?

វាអាស្រ័យទៅលើមនុស្សម្នាក់ៗ។

- មនុស្សដែលមានប្រតិកម្មអាលែកហ្ស៊ីទៅនឹងវត្ថុមួយចំនួនដូចជាថ្នាំលេប អាហារ (រួមទាំងស៊ុត) សារ

ធាតុជ័រ សត្វចិញ្ចឹម ឬលម្អងផ្កា ឬមនុស្សដែលមានប្រវត្តិគ្រួសារទាក់ទងនឹងប្រតិកម្មឬការទាស់ ក៏អាចចាក់ថ្នាំបង្ការបានដែរ។ គ្មានថ្នាំបង្ការណាមួយមានផ្ទុកស៊ុត ចាហួយ ជ័រកៅស៊ូ ឬសារធាតុគីមីទុកកុំឱ្យខូចឡើយ។

- មនុស្សដែលមានប្រតិកម្មឬការទាស់ទៅនឹងថ្នាំបង្ការ ឬការព្យាបាលចាក់តាមម្ជុល (ទោះបីមិនមានសភាពធ្ងន់ធ្ងរក៏ដោយ) គួរតែពិគ្រោះជាមួយគ្រូពេទ្យដើម្បីសម្រេចថា តើវាមានសុវត្ថិភាពក្នុងការចាក់ថ្នាំបង្ការដែរឬទេ។
- មនុស្សដែលមានប្រតិកម្មឬការទាស់ជាមួយសារធាតុចម្រាញ់ពីប្រេងប៉ូលីអេស៊ីលីនគ្លីកូល (Polyethylene Glycol, PEG) មិនគួរចាក់ថ្នាំបង្ការប្រភេទ Pfizer (ឬប្រភេទ COMIRNATY) ឬ Moderna ទេ។ ពួកគេគួរតែពិគ្រោះជាមួយគ្រូពេទ្យដើម្បីមើលថា តើពួកគេអាចទទួលថ្នាំបង្ការប្រភេទ J&J បានដែរឬទេ។
- មនុស្សដែលមានប្រតិកម្មឬការទាស់ជាមួយល្បាយប៉ូលីសរបឺត (polysorbate) មិនគួរចាក់ថ្នាំបង្ការប្រភេទ J&J នោះទេ។ ពួកគេគួរតែពិគ្រោះជាមួយគ្រូពេទ្យដើម្បីមើលថា តើពួកគេអាចទទួលបានថ្នាំបង្ការប្រភេទ Pfizer ឬ Moderna បានដែរឬទេ។

យុវជនដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំអាចទទួលបានតែការចាក់ថ្នាំបង្ការប្រភេទ Pfizer ប៉ុណ្ណោះនៅពេលនេះ។

អាចប្រឈមនឹងហានិភ័យតិចតួចសម្រាប់អាណាហ្វីឡាក់ស៊ីស (anaphylaxis) (ជាប្រភេទប្រតិកម្មឬការទាស់បែបធ្ងន់ធ្ងរ) ដោយសារថ្នាំបង្ការណាមួយក៏ដោយ។ នេះជាមូលហេតុដែលមនុស្សគ្រប់គ្នាត្រូវបានស្ថិតក្រោមការសង្កេតមើលក្នុងរយៈពេលខ្លី បន្ទាប់ពីចាក់ថ្នាំបង្ការជំងឺ COVID-19។

ព័ត៌មានអំពីប្រតិកម្មឬការទាស់ អាចមានការប្រែប្រួល។ សម្រាប់ព័ត៌មានលម្អិត និងដើម្បីពិនិត្យមើលសេចក្តីណែនាំថ្មីជាងគេ សូមមើលគេហទំព័រ ថ្នាំបង្ការជំងឺ COVID-19 សម្រាប់បុគ្គលដែលមានប្រតិកម្ម របស់ CDC ហើយពិគ្រោះជាមួយគ្រូពេទ្យ។

### តើមានអ្វីខ្លះនៅក្នុងថ្នាំបង្ការ?

សម្រាប់តារាងរូបមន្តទាំងមូល សូមមើលទំព័រព័ត៌មានពិតនីមួយៗរបស់ថ្នាំបង្ការសម្រាប់អ្នកទទួល និងអ្នកផ្តល់ការថែទាំ៖ ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer-BioNTech ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Moderna និងថ្នាំបង្ការជំងឺ COVID-19 ប្រភេទ J&J/Janssen។ ថ្នាំបង្ការប្រភេទ Pfizer (ឬប្រភេទ COMIRNATY) និងប្រភេទ Moderna មានផ្ទុកនូវសារធាតុចម្រាញ់ពីប្រេងប៉ូលីអេស៊ីលីនគ្លីកូល (Polyethylene Glycol, PEG) និងថ្នាំបង្ការប្រភេទ J&J មានផ្ទុកសារធាតុល្បាយប៉ូលីសរបឺត (polysorbate)។ ថ្នាំបង្ការនេះមិនមានផ្ទុកស៊ុត ចាហួយ ជ័រកៅស៊ូ ឬសារធាតុគីមីទុកកុំឱ្យខូចឡើយ។

### កូនរបស់ខ្ញុំធ្លាប់មានជំងឺ COVID-19 រួចហើយ តើពួកគេគួរតែចាក់ថ្នាំបង្ការដែរឬទេ?

ចាស/បាទ គួរតែចាក់។ កូនរបស់អ្នកគួរតែចាក់ថ្នាំបង្ការ ទោះបីជាពួកគេធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ។ យើងមិនដឹងទេថា តើមនុស្សម្នាក់នឹងអាចមានប្រព័ន្ធការពាររយៈពេលប៉ុន្មានទេ បន្ទាប់ពីមានជំងឺ COVID-19 រួចមក។ ការចាក់ថ្នាំបង្ការនឹងជួយបង្កើនភាពស៊ាំរបស់ពួកគេ និងផ្តល់ឱ្យពួកគេនូវការការពារកាន់តែប្រសើរ និងយូរអង្វែងប្រឆាំងនឹងជំងឺ COVID-19។ នេះរួមបញ្ចូលទាំងការការពារប្រឆាំងនឹងមេរោគប្រភេទថ្មីៗដែលងាយនឹងឆ្លង ឬអាចបង្កឱ្យធ្លាក់ខ្លួនឈឺកាន់តែធ្ងន់ធ្ងរជាងមុន។

### តើវាមានសុវត្ថិភាពដែរឬទេ សម្រាប់កុមារដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំទទួលចាក់ថ្នាំបង្ការ?

ចាស/បាទ គឺមានសុវត្ថិភាព។ បន្ទាប់ពីការធ្វើតេស្តសាកល្បងបែបវេជ្ជសាស្ត្រ (clinical trials) យ៉ាងហ្មត់ចត់ ថ្នាំបង្ការជំងឺ COVID-19 របស់ Pfizer - ជាថ្នាំបង្ការដូចគ្នាដែលត្រូវបានផ្តល់ជូន ដល់មនុស្សពេញវ័យរាប់លាននាក់ដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅដោយសុវត្ថិភាពនោះ - ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយ FDA សម្រាប់យុវជនដែលមានអាយុ 12 ដល់ 15 ឆ្នាំកាលពីខែឧសភា។ ការសិក្សានានាបានបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 របស់ Pfizer មានសុវត្ថិភាព និង មានប្រសិទ្ធភាព សម្រាប់កុមារដែលមានអាយុចាប់ពី 12 ដល់ 17 ឆ្នាំ ក៏ដូចជាមនុស្សពេញវ័យផងដែរ។ ឥឡូវនេះ ថ្នាំបង្ការទទួលបានការអនុម័តទាំងស្រុងពី FDA សម្រាប់មនុស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ហើយបន្តទទួលការត្រួតពិនិត្យលើសុវត្ថិភាព។

ឪពុកម្តាយគួរតែដឹងពីរបាយការណ៍អំពីបញ្ហារលាកសាច់ដុំបេះដូង (myocarditis) ឬស្រទាប់ខាងក្រៅនៃបេះដូង (pericarditis) ចំពោះមនុស្សដែលទទួលការចាក់ថ្នាំបង្ការប្រភេទ Pfizer និង Moderna។ របាយការណ៍ទាំងនេះកម្រមានណាស់ ប្រសិនបើគិតដល់ចំនួនដូសថ្នាំបង្ការដែលបានផ្តល់ជូននោះ។ ករណីភាគច្រើនគឺកើតលើបុរសវ័យជំទង់ និងមនុស្សពេញវ័យនៅក្មេង ហើយភាគច្រើនបានកើតឡើងប៉ុន្មានថ្ងៃបន្ទាប់ពីចាក់ថ្នាំបង្ការ និងជាញឹកញាប់បន្ទាប់ពីការចាក់ដូសទីពីរ។ ប្រសិនបើមនុស្សវ័យជំទង់ ឬបុគ្គលណាម្នាក់ផ្សេងទៀតមានរោគសញ្ញាណាមួយដូចខាងក្រោម បន្ទាប់ពីចាក់ថ្នាំបង្ការរួច ពួកគេត្រូវបានណែនាំឱ្យស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រភ្លាមៗ៖

- ឈឺទ្រូង
- ការដកដង្ហើមខ្លីៗ
- អារម្មណ៍នៃបេះដូងលោតញាប់ ឡើងចុះខ្លាំង ឬលោតខ្លាំង។

អ្នកជំងឺភាគច្រើនដែលមានបញ្ហារលាកសាច់ដុំបេះដូង និងបញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូងដែលបានទទួលការថែទាំ អាចមានការប្រសើរឡើងវិញដោយប្រើថ្នាំ និងសម្រាកព្យាបាល ហើយនឹងមានអារម្មណ៍ធូរស្បើយឆាប់រហ័ស។ អ្នកដែលជួបប្រទះស្ថានភាពទាំងនេះ ជាទូទៅ អាចវិលទៅរកសកម្មភាពប្រចាំថ្ងៃធម្មតារបស់ពួកគេវិញបន្ទាប់ពីរោគសញ្ញារបស់ពួកគេមានភាពប្រសើរឡើង ប៉ុន្តែពួកគេគួរតែជួបពិភាក្សាជាមួយគ្រូពេទ្យឯកទេសជំងឺបេះដូង (គ្រូពេទ្យបេះដូង) មុនពេលត្រឡប់ទៅហាត់ប្រាណ ឬលេងកីឡាវិញ។ វាជាការសំខាន់ក្នុងការកត់សម្គាល់ថាជំងឺរលាកសាច់ដុំបេះដូង និងជំងឺរលាកស្រទាប់ក្រៅនៃបេះដូង ទំនងជាកើតឡើងលើមនុស្សដែលមានជំងឺ COVID-19 ជាង ហើយហានិភ័យដល់បេះដូងដោយការឆ្លងជំងឺ COVID-19 អាចមានសភាពកាន់តែធ្ងន់ធ្ងរ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័ររបស់ CDC ស្តីអំពី ជំងឺរលាកសាច់ដុំបេះដូង និងជំងឺរលាកស្រទាប់ក្រៅនៃបេះដូងបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ mRNA។

ផលប៉ះពាល់ដ៏កម្រមួយទៀតគឺអាណាហ្វីឡាក់ស៊ីស (anaphylaxis)។ នេះគឺជាប្រតិកម្មឬការទាស់បែបធ្ងន់ធ្ងរមួយដែលអាចកើតឡើងបន្ទាប់ពីចាក់ថ្នាំបង្ការរួច។ មនុស្សគ្រប់រូបត្រូវបានពិនិត្យសង្កេតក្នុងរយៈពេលខ្លីបន្ទាប់ពីបានចាក់ថ្នាំបង្ការជំងឺ COVID-19 ដូច្នេះប្រសិនបើមានប្រតិកម្មអាណាហ្វីឡាក់ស៊ីសកើតឡើងមែននោះ ពួកគេអាចទទួលបានការព្យាបាលភ្លាមៗ។ ស្វែងយល់បន្ថែមនៅលើគេហទំព័ររបស់ CDC តើត្រូវធ្វើយ៉ាងណា ប្រសិនបើអ្នកមានប្រតិកម្មឬការទាស់បន្ទាប់ពីបានចាក់ថ្នាំបង្ការជំងឺ COVID-19។

CDC បន្តណែនាំឱ្យមានការ ចាក់ថ្នាំបង្ការជំងឺ COVID-19 សម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ។ ហានិភ័យដែលត្រូវបានរកឃើញអំពីជំងឺ COVID-19 និងផលវិបាកដែលពាក់ព័ន្ធ ហើយអាចមានភាពធ្ងន់ធ្ងរផ្សេងទៀតរបស់មេរោគនេះ (ដូចជាបញ្ហាសុខភាពរយៈពេលវែង ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ផងនោះ) គឺមានលើសច្រើនណាស់ពីហានិភ័យដែលអាចកើតឡើយដោយប្រតិកម្មមិនល្អ ដែលកម្រ មួយចំនួនចំពោះការចាក់ថ្នាំបង្ការ រួមទាំងហានិភ័យដែលអាចកើតមាននៃបញ្ហារលាកសាច់ដុំបេះដូង ឬបញ្ហារលាកស្រទាប់ក្រៅនៃបេះដូងផងដែរ។

### តើកូនរបស់ខ្ញុំអាចកើតជំងឺ COVID-19 ពីការចាក់ថ្នាំបង្ការដែរឬទេ?

កូនរបស់អ្នកមិនអាចកើតជំងឺ COVID-19 ពីការថ្នាំបង្ការនេះទេ។ វាមិនអាចទៅរួចទេ ពីព្រោះគ្មានថ្នាំបង្ការណាមួយដែលត្រូវបានប្រើនៅសហរដ្ឋអាមេរិក មានផ្ទុកនូវទម្រង់ណាមួយនៃមេរោគដែលបង្កឱ្យមានជំងឺ COVID-19 ឡើយ។

### តើថ្នាំបង្ការបណ្តាលឱ្យគ្មានកូនដែរឬទេ?

មិនមានហេតុផលផ្នែកជីវសាស្ត្រ ឬភស្តុតាងណាមួយដែលបង្ហាញថា ថ្នាំបង្ការណាមួយ រួមទាំងថ្នាំបង្ការជំងឺ COVID-19 អាចបណ្តាលឱ្យមានបញ្ហាការបង្កកំណើតចំពោះស្ត្រី ឬបុរសនោះឡើយ។ មនុស្សមួយចំនួនដែលបានចាក់ថ្នាំបង្ការក្នុងអំឡុងពេលនៃការធ្វើតេស្តសាកល្បងបែបវេជ្ជសាស្ត្រ (clinical trials) សម្រាប់ថ្នាំបង្ការជំងឺ COVID-19 និងមនុស្សជាច្រើនដែលបានទទួលថ្នាំបង្ការចាប់តាំងពីការសាកល្បងនោះបានមានផ្ទៃពោះ។ ថ្នាំបង្ការមិនផ្លាស់ប្តូរ DNA របស់មនុស្សណាមួយឡើយ ហើយក៏មិនមានភស្តុតាងណាមួយដែលពួកគេជះឥទ្ធិពលទៅលើការលូតលាស់របស់មនុស្សវ័យជំទង់ដែរ។

### តើថ្នាំបង្ការជំងឺ COVID-19 អាចប៉ះពាល់ដល់ការមករដូវរបស់កូនខ្ញុំដែរឬទេ?

មនុស្សមួយចំនួនបានរាយការណ៍ពីការផ្លាស់ប្តូររដូវរបស់ពួកគេ បន្ទាប់ពីចាក់ថ្នាំបង្ការ រួមទាំងការធ្លាក់ឈាមច្រើន និងរមួលឈឺចាប់ខ្លាំង។ យើងមិនទាន់ដឹងថា តើការផ្លាស់ប្តូរទាំងនេះគឺដោយសារតែថ្នាំបង្ការទេ - ការផ្លាស់ប្តូររដូវមិនបានត្រូវគេរាយការណ៍ពីការសាកល្បងថ្នាំបង្ការទេ ហើយមិនទាន់មានលទ្ធផលនៃការសិក្សាទៅលើបញ្ហានេះនៅឡើយដែរ។ វាជាការសំខាន់ដែលត្រូវចងចាំថា មានរឿងជាច្រើនអាចបណ្តាលឱ្យមានការផ្លាស់ប្តូរវដ្តរដូវ ដូចជាភាពតានតឹង និងការផ្លាស់ប្តូរដំណេក របបអាហារ ការធ្វើលំហាត់ប្រាណ និងថ្នាំមួយចំនួន ហើយការមករដូវមិនទៀងទាត់គឺជារឿងធម្មតាណាស់ក្នុងចំណោមក្មេងវ័យជំទង់។ ប្រសិនបើកូនរបស់អ្នកមានការព្រួយបារម្ភពីរដូវរបស់ពួកគេ មានការណែនាំឱ្យពួកគេពិភាក្សាជាមួយគ្រូពេទ្យរបស់ពួកគេ ។

### ថ្នាំបង្ការជំងឺ COVID-19 នឹងមានផលប៉ះពាល់រយៈពេលវែងដល់កូនរបស់ខ្ញុំដែរឬទេ?
ផលប៉ះពាល់រយៈពេលវែង បន្ទាប់ពីការចាក់ថ្នាំបង្ការណាមួយគឺកម្រកើតមានណាស់។ ផ្អែកលើអ្វីដែលយើងដឹងពីថ្នាំបង្ការផ្សេងទៀត ផលប៉ះពាល់ដែលកម្រហើយអាចកើតមានរយៈពេលវែង ជាធម្មតាចាប់ផ្តើមលេចឡើងក្នុងរយៈពេលប្រាំមួយសប្តាហ៍បន្ទាប់ពីចាក់ថ្នាំបង្ការ។ ដោយហេតុផលនេះ រដ្ឋបាលចំណីអាហារ និងឱសថ (FDA) បានតម្រូវឱ្យថ្នាំបង្ការជំងឺ COVID-19 នីមួយៗត្រូវបានសិក្សាយ៉ាងហោចណាស់ប្រាំបីសប្តាហ៍បន្ទាប់ពីការចាក់ដូសចុងក្រោយ មុនពេលពួកគេផ្តល់សិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់។ មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) បន្តតាមដានថ្នាំបង្ការជំងឺ COVID-19 បន្ទាប់ពីពួកគេត្រូវបានផ្តល់សិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ ខណៈពេលដែលថ្នាំបង្ការត្រូវបានប្រើលើមនុស្សកាន់តែច្រើនឡើងៗ។ ប្រសិនបើបានរកឃើញបញ្ហាសុវត្ថិភាពលើថ្នាំបង្ការណាមួយ FDA និងក្រុមហ៊ុនផលិតថ្នាំបង្ការនឹងសហការគ្នាដើម្បីរកដំណោះស្រាយសមស្របសម្រាប់ការព្រួយបារម្ភអំពីសុវត្ថិភាពនោះ (ឧទាហរណ៍ បញ្ហាសំណុំផលិតផលជាក់លាក់ណាមួយ បញ្ហាក្នុងពេលផលិតកម្ម ឬបញ្ហាថ្នាំបង្ការដោយផ្ទាល់តែម្តង)។

### ប្រសិនបើកូនរបស់ខ្ញុំមានប្រតិកម្មមិនល្អមួយ (ផលប៉ះពាល់ដែលអាចកើតមាន) បន្ទាប់ពីពួកគេបានចាក់ថ្នាំបង្ការ តើខ្ញុំគួររាយការណ៍វាយ៉ាងដូចម្តេច?
ប្រសិនបើកូនរបស់អ្នកមានប្រតិកម្មមិនល្អមួយបន្ទាប់ពីបានចាក់ថ្នាំបង្ការ សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ហើយរាយការណ៍ពីប្រតិកម្មនោះទៅ ប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍មិនល្អនៃថ្នាំបង្ការ (ឬ VAERS)។ រាយការណ៍ផលប៉ះពាល់នេះទោះបីជាអ្នកមិនប្រាកដថាថ្នាំបង្ការជាអ្នកបង្កឱ្យមានក៏ដោយ។ VAERS គឺជាប្រព័ន្ធប្រាប់ឱ្យដឹងមុនដែល FDA និង CDC ប្រើប្រាស់ដើម្បីរកបញ្ហាសុវត្ថិភាពដែលអាចកើតមានដោយថ្នាំបង្ការណាមួយ។ ដើម្បីធ្វើរបាយការណ៍ សូមទូរស័ព្ទទៅលេខ 1-800-822-7967 ឬចូលទៅកាន់គេហទំព័រ៖ https://vaers.hhs.gov/reportevent.html។

ប្រសិនបើអ្នកមានទូរស័ព្ទទំនើប អ្នកអាចជួយ CDC ពិនិត្យតាមដានថ្នាំបង្ការនានាតាមរយៈការចុះឈ្មោះកូនរបស់អ្នកក្នុងកម្មវិធី V-Safe។ **V-safe** គឺជាកម្មវិធីដែលត្រូវបានប្រើប្រាស់លើទូរស័ព្ទទំនើបដោយផ្ញើសារជាអក្សរដើម្បីពិនិត្យមើលកូនរបស់អ្នក បន្ទាប់ពីពួកគេបានចាក់ថ្នាំបង្ការ។ កុមារម្នាក់ៗគួរតែត្រូវបានចុះឈ្មោះដាច់ដោយឡែករៀងៗខ្លួន។ រាល់សារជាអក្សររបស់ **v-safe** ត្រូវបានផ្ញើទៅទូរស័ព្ទទំនើបរបស់ឪពុកម្តាយ ឬអាណាព្យាបាលដោយផ្ទាល់។

ប្រព័ន្ធ VAERS និងកម្មវិធី V-safe មិនគួរប្រើប្រាស់សម្រាប់ការណែនាំលើផ្នែកវេជ្ជសាស្ត្រទេ។ ប្រសិនបើកូនរបស់អ្នកមានរោគសញ្ញា ឬបញ្ហាសុខភាពដែលធ្វើឱ្យអ្នកព្រួយបារម្ភបន្ទាប់ពីចាក់ថ្នាំបង្ការជំងឺ COVID-19 ហើយ សូមទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក ឬស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។

### តើខ្ញុំត្រូវនិយាយជាមួយកូនរបស់ខ្ញុំអំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 យ៉ាងដូចម្តេច?
វាមានសារៈសំខាន់ណាស់សម្រាប់យុវជនក្នុងការដឹងពីការពិតអំពីថ្នាំបង្ការជំងឺ COVID-19។ មានការផ្សាយព័ត៌មានមិនពិតជាច្រើនអំពីជំងឺ COVID-19 និងថ្នាំបង្ការជំងឺនេះ ដែលត្រូវបានផ្សព្វផ្សាយនៅលើអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ត្រូវប្រាកដថា និយាយជាមួយកូនដែលមានវ័យជំទង់របស់អ្នកអំពីជំងឺ COVID-19 ហើយឆ្លើយនូវរាល់សំណួរដែលពួកគេអាចមាន។

សូមឱ្យពួកគេដឹងអំពីហានិភ័យនៃសុខភាព ប្រសិនបើមាននរណាម្នាក់កើតជំងឺ COVID-19 និងមូលហេតុដែលថាការចាក់ថ្នាំបង្ការអាចជួយការពារពួកគេបាន។ ចូរពន្យល់ថាថ្នាំបង្ការនេះមានសុវត្ថិភាព ហើយវាមិនមានផ្ទុកមេរោគទេ។ ចូរពន្យល់អំពីផលប៉ះពាល់ជាមួយពួកគេឡើងវិញ ហើយឱ្យពួកគេដឹងថាផលប៉ះពាល់ទាំងនេះជារឿងធម្មតា។ លួងលោមពួកគេ ប្រសិនបើពួកគេភ័យខ្លាចចំពោះការចាក់ថ្នាំបង្ការ។

រំលឹកពួកគេថា ការចាក់ថ្នាំបង្ការនឹងជួយការពារគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។ វាក៏នឹងធ្វើឱ្យពួកគេមានសុវត្ថិភាពជាងមុនក្នុងការធ្វើអ្វីផ្សេងៗ ដូចជាការលេងកីឡា ជួបជុំជាមួយមិត្តភក្តិ និងទៅសួរសុខទុក្ខក្រុមគ្រួសារផងដែរ។

ប្រសិនបើពួកគេមានសំណួរ ឬកង្វល់ វាជាគំនិតល្អមួយដើម្បីឱ្យពួកគេពិគ្រោះជាមួយមនុស្សដែលមានចំណេះដឹង និងគួរឱ្យទុកចិត្តបាន ដូចជាគ្រូពេទ្យប្រចាំគ្រួសារ ឬគ្រូពេទ្យជំនាញខាងកុមារ។